**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ: ២២៥៥ រ.ន.ស/គ.រ.ជ.ន.ជ.

ថ្ងៃអង្គារ ៩ កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨

**ជម្រាបជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ**

**កម្មវត្ថុ:** សេចក្តីណែនាំបន្ថែមស្តីពីការរៀបចំការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទ នៅខេត្តព្រះសីហនុ

**យោង:**
- ព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ ជ្រាបថា ដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព ជាសុភភាព សោភ័ណភាព និងសុវត្ថិភាព នៅខេត្តព្រះសីហនុ រាល់ការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទ ត្រូវ÷

១. ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់កម្ពស់យ៉ាងតិច ២ (ពីរ) ម៉ែត្រ ពីនីវ៉ូ ០ (សូន្យ) នៃគម្រោង ដែលក្នុងនេះត្រូវរៀបជើងរបងអំពីថ្មកម្ពស់យ៉ាងតិច ៨០ (ប៉ែតសិប) សង់ទីម៉ែត្រ ដើម្បីកុំឱ្យដី សំណល់រឹងនិងរាវ ហៀរចេញពីការដ្ឋានទៅលើផ្លូវ ចិញ្ចើមផ្លូវ ដីចំណីឆ្នេរ ឆ្នេរសមុទ្រ សមុទ្រ ព្រែក អូរ បឹង និងទីតាំងសាធារណៈ ក្នុងគោលដៅធានាសុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ សោភ័ណភាព និងបរិស្ថានសាធារណៈ។

២. រក្សាទុកចញ្ចើមផ្លូវឱ្យបានទូលាយយ៉ាងតិចស្មើនឹងពីរភាគបីនៃប្រវែងទទឹងចិញ្ចើមផ្លូវ សម្រាប់ឱ្យអ្នកថ្មើរជើងធ្វើដំណើរប្រកបដោយសុវត្ថិភាព។

៣. រៀបចំទុកដាក់សម្ភារៈសំណង់ គ្រឿងចក្រ ឧបករណ៍សាងសង់ ការិយាល័យការងារ រោងជាងកន្លែងស្នាក់នៅរបស់កម្មករ ក្នុងបរិវេណរបងហ៊ុំព័ទ្ធការដ្ឋានសាងសង់។



ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

៤. គ្រប់គ្រងសំណល់រឹងនិងរាវ ដោយរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធលូសម្រាប់ការដ្ឋានសាងសង់មុននឹងបង្ហូរចេញទៅប្រព័ន្ធលូសាធារណៈ ស្របតាមបទដ្ឋានបច្ចេកទេសសំណង់ និងបរិស្ថាន។

៥. រក្សាសុវត្ថិភាព សណ្ដាប់ធ្នាប់ អនាម័យ សោភ័ណភាព បរិស្ថានល្អ និងសុខដុមរមនាជាមួយនឹងអ្នកជិតខាង និងសាធារណៈ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សូម **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត ទទួលនូវការរាប់អានពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**ចម្លងជូន:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងទេសចរណ៍
- ក្រសួងបរិស្ថាន
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ
- ឯកសារ កាលប្បវត្តិ